# ១៧- រឿង ស្រីមានសហាយ ៗ ស្លាប់

មាននិទានមួយថា : មានបុរសម្នាក់និងស្រីម្នាក់ជាស្នន់អន្ទករផងគ្នា លួចទៅមករកគ្នា ម្ដាយឪពុកពុំដឹងឡើយ ។ មានកាលមួយថ្ងៃ ខ្លែងឆាបពស់វែកឆី វាហើរមកជ្រុះពស់លើដំបូលផ្ទះស្រីនោះ ។ ក្នុងរាត្រីនោះឯងបុរសនោះទៅកាន់ផ្ទះមេស្នន់អន្ទករ គាប់ចូនភ្លៀងធំ បុរសនោះស្រេកទឹកប្រើមេស្នន់អន្ទករទៅសិតទឹកឲ្យ ។ មេស្នន់អន្ទករពុំទៅសិតទឹកអំពីក្អមយកសៀនទៅត្រងទឹកភ្លៀងនៅរងស្បូវ ត្រូវឆ្អឹងពស់វែកនោះ ទឹកភ្លៀងដូចគេលាងពិសពស់ហូរចូលទៅក្នុងសៀន ។ មេស្នន់អន្ទករមិនបានដឹង ក៏យកមកឲ្យបុរសនោះផឹក ។ កម្លាំងពិសពស់ខ្លាំង បុរសនោះក៏ហាល់ផ្ទៃស្លាប់ទៅ ។ មេស្នន់អន្ទករបីខ្មោចបុរសនោះយកទៅដាក់នៅកណ្ដាលផ្លូវ ។ លុះព្រឹកឡើង ឪពុកម្ដាយបុរសស្លាប់នោះ ដឹងថាកូនបាត់ហើយដើរខ្មីឃ្មាតទៅរក បានឃើញខ្មោចកូននៅកណ្ដាលផ្លូវក៏ភិតភ័យរលះរលាំងទៅប្ដឹងចៅក្រម ។ ឯចៅក្រមដណ្ដឹងថា "កូននោះស្លាប់ដោយមានហេតុឬឥតហេតុ ?" ។ ម្ដាយឪពុកឆ្លើយថា " ខ្ញុំពុំឃើញហេតុអ្វីទេ " ។ ចៅក្រមថា " បើឥតហេតុដូច្នោះយើងនឹងជំនុំជម្រះឲ្យពុំបាន " ។ ទើបឪពុកម្ដាយប្ដឹងចៅក្រម ឲ្យនាំខ្លួនឡើងទៅគាល់ព្រះមហាក្សត្រហើយក្រាបបង្គំទូលថា " សូមទ្រង់ព្រះអង្គមេត្តាប្រោស, កូនខ្ញុំព្រះបាទអម្ចាស់នេះស្លាប់នៅកណ្ដាលផ្លូវ ចៅក្រមពិចារណារកឲ្យខ្ញុំព្រះបាទអម្ចាស់ពុំបានឡើយ ទើបខ្ញុំព្រះបាទអម្ចាស់មកក្រាបទូលព្រះបាទអម្ចាស់ពុំចេះសូមទ្រង់ព្រះពិចារណា" ។ ទើបព្រះមហាក្សត្រទ្រង់មានព្រះបន្ទូលថា "បើអស់ចៅក្រមទាំងអម្បាលម៉ាននោះជំនុំពិចារណាក្ដីនេះពុំបាន ក៏អញនឹងពិចារណាខ្លួនឯង" ទើបព្រះអង្គឲ្យហៅកំលោះរាជានុកូលម្នាក់មកហើយទ្រង់មានព្រះបន្ទូលថា "ចូរព្រះស្ដែងយកខ្មោចបុរសនោះទៅដាក់លើផ្ទះឪពុកម្ដាយ ហើយប្រាប់អស់ទាំងស្រីផងឲ្យទៅយំសោកក្បែរខ្មោចបុរសនោះ ហើយព្រះស្ដែងចាំស្ដាប់ទំនួញអស់ស្រីទាំងនោះវាយំទួញថាម្ដេចៗ ខ្លះ ? ស្រីណាយំសោកស្ដាយថាម្ដេច ព្រះស្ដែងកត់ត្រាឈ្មោះអស់ស្រីអម្បាលនោះសព្វគ្រប់យកមកឲ្យអញ" ។ ឯចៅកំលោះរាជានុកូលនោះ ក្រាបថ្វាយបង្គំទទួលព្រះបន្ទូលចេញទៅយកខ្មោចបុរសនោះទៅដាក់លើផ្ទះម្ដាយឪពុក ហើយប្រាប់អស់ស្រីផងឲ្យមកយំសោក ខ្មោចនោះដូចព្រះបន្ទូល ។ អស់ស្រីឯទៀតមកយំហើយទៅផ្ទះទីទៃ ៗ ទៅនៅតែមេម្នាក់យំសោកអាល័យពុំអស់សេចក្ដីពុំទៅផ្ទះ ឱបខ្មោចទួញយំនៅទីនោះ ។ កំលោះរាជានុកូល កត់ដោយដំណើរហើយយកទៅទូលព្រះមហាក្សត្រ ព្រះអង្គជ្រាបដោយដំណើរនោះហើយ ទ្រង់មានព្រះបន្ទូលឲ្យទៅដណ្ដឹងមេនោះថា " ត្រូវជាសាច់ញាតិម្ដេចនិងខ្មោចនោះ បានជាឱបទួញយំពុំទៅផ្ទះ" ។ មេនោះឆ្លើយថា " ពុំជាសាច់ញាតិទេ ត្បិតចៅនេះជាស្នន់អន្ទករនឹងខ្ញុំ ទៅរកខ្ញុំចូនភ្លៀងធំ ចៅនេះស្រេកទឹក ខ្ញុំយកសៀនត្រង់ទឹកភ្លៀងឲ្យចៅនេះ ៗ នេះផឹកហើយ ស្រាប់តែហាល់ផ្ទៃស្លាប់យប់នោះឯង ខ្ញុំយកខ្មោចទៅដាក់នៅកណ្ដាលផ្លូវ ខ្ញុំស្រណោះបុរសនេះឯងទើបខ្ញុំយំ " ។ កំលោះរាជានុកូលក៏នាំពាក្យទាំងនេះ ទៅក្រាបទូលព្រះមហាក្សត្រ ។ ព្រះអង្គបានជ្រាបអស់ដំណើរដូច្នោះហើយទើបព្រះអង្គឲ្យមកមើលលើដំបូលផ្ទះស្នន់អន្ទករនោះ ឃើញមានឆ្អឹងពស់វែកនៅទីដែលមេស្នន់អន្ទករត្រងទឹកភ្លៀងឲ្យបុរសនោះផឹក ទើបទ្រង់មានព្រះបន្ទូលថា "នេះហេតុកម្មបុរាណខ្លួនឯងមកផ្ដល់ " ឯមេស្នន់អន្ទករនោះពុំធ្វើថ្នាំបំពុលឡើយ" ។ ព្រះអង្គពុំឲ្យឪពុកម្ដាយបុរសស្លាប់នោះនាំមេស្នន់អន្ទករនោះជាក្ដីឡើយ បើឲ្យមេស្នន់អន្ទករនោះទៅលំនៅអាត្មាទីទៃ ៗ ហោង ។